សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ការផ្សះផ្សាជាតិមានប្រសិទ្ធិភាព លុះត្រាតែមានយុត្តិធម៌ក្នុងសង្គម ។

www.hoksavann.org

ថ្ងៃទី១៤ ធ្នូ ២០១១



មានបញ្ហាលើកឡើងថា ជនជាតិខ្មែរកាន់ព្រះពុទ្ធសាសនា ហេតុអ្វីបានជាមានការកាប់សម្លាប់គ្នា រហូតជនជាតិខ្មែររាប់លាននាក់បានត្រូវស្លាប់ ។ តាមការពិត ការសម្លាប់គ្នា ជាពិសេសសម័យវាលពិឃាតខ្មែរក្រហម ពុំទាក់ទងនឹងព្រះពុទ្ធសាសនាឡើយ ការពិតអ្នកពុទ្ធសាសនាត្រូវទទួលរងគ្រោះវិញទេ ។ តាមព្រះពុទ្ធសាសនា ព្រះពុទ្ធជាម្ចាស់បានបង្រៀនមនុស្សកុំឲ្យសម្លាប់គ្នា រហូតហាមសម្លាប់សត្វថែមទៀត ។ ខ្មែរក្រហមកុម្មុយនិស្តដណ្តើមអំណាចបាន ដោយសារប្រជាប្រិយភាពរបស់ព្រះមហាវីរក្សត្រសម្តេចសីហនុ ដោយពលរដ្ឋខ្មែរពេលនោះជួយឲ្យឈ្នះ ដោយយល់ច្រឡំថាយកអំណាចថ្វាយព្រះអង្គវិញ ហើយបុព្វហេតុមួយទៀតដែលនាំឲ្យឈ្នះ គឺដោយព្រឹត្តិការណ៍ពេលនោះរុញច្រានផង ។ ដូចនេះ ពុទ្ធសាសនិកជនខ្មែរពុំគាំទ្រខ្មែរក្រហមឲ្យឈ្នះ ហើយឡើងកាន់អំណាចឡើយ ។ ពេលខ្មែរក្រហមបានអំណាច ពួកនេះបានបង្កើតគំនុំសងសឹករវាងខ្មែរនិងខ្មែរ ដូចបង្កើតពាក្យថា កំទេចខ្មាំងវាយរបបកំចាត់ចក្រពត្តិមូលធនសក្តិភូមិ ។ គេចាត់អ្នកកាន់ព្រះពុទ្ធសាសនា ជាក្រុមសក្តិភូមិជិះជាន់គេ ដូច្នេះគេត្រូវតែបំបាត់ព្រះពុទ្ធសាសនា ដែលផ្ទុយពីពាក្យនួន-ជាដែលឆ្លើយដោះសារក្នុងវង្វង់ក្រចកសេះថា របបរបស់គាត់ការពារព្រះពុទ្ធសាសនា ។ ទោះបីគាត់ឆ្លើយដោះសារថា ខ្មែររាប់លាននាក់ដែលស្លាប់នោះ ពុំមែនខ្មែរក្រហមសម្លាប់ទេ គឺវៀតណាមជាអ្នកសម្លាប់យ៉ាងនេះក៏ដោយ ក៏ខ្មែរក្រហមត្រូវតែទទួលខុសត្រូវចំពោះសោកនាដកម្មរបស់ពលរដ្ឋខ្មែរក្នុងពេលគ្រប់គ្រងរបស់ខ្លួន ។ នួន-ជាបានឆ្លើយតបទៅកាន់សហព្រះរាជអាជ្ញារថា ការចោទប្រកាន់គាត់ពុំត្រឹមត្រូវ គ្មានភស្តុតាង គ្មានសាក្សី ចេះតែថាតាមសៀវភៅប្រវត្តិសាស្ត្រនិងសារពត៌មាន ។ ផ្ទុយពីមាត់គាត់ ការពិតប្រជាពលរដ្ឋខ្មែរទាំងមូលដែលទទួលរងគ្រោះជាសាក្សី ជាមួយនិងរណ្តៅកប់សពធំៗជាច្រើនកន្លែងនៅពាសពេញប្រទេសកម្ពុជា ។ ប៉ុន្តែសំដីនួន-ជាមួយឃ្លាហាក់ដូចទទួលសារភាព អំពីការដេញព្រះសង្ឃនិងប្រជាជនខ្មែរពីទីក្រុង និងពាក្យកំទេចខ្មាំងដើម្បីការពារជាតិ ។ តើអ្នកណាជាខ្មាំង គឺព្រះសង្ឃនិងពលរដ្ឋខ្មែរដែលជាសត្រូវវណ្ណៈអធនរបស់គណបក្សគាត់នេះឯង ។

យើងជាអ្នកកាន់ព្រះពុទ្ធសាសនា សូមគាំទ្រតុលាការកាត់ក្តីចំរុះនេះ ទោះបីគេមើលឃើញថា តុលាការនេះបានកំណត់អ្នកដែលត្រូវយកមកកាត់ទោស ពុំអាចរកយុត្តិធម៌ជូនអ្នករងគ្រោះឲ្យបានពេលលេញក៏ដោយ ។ ការគាំទ្រនេះពុំបានន័យថា ចងពៀរនឹងខ្មែរក្រហមឡើយ តែជាការគាំទ្រយុត្តិធម៌របស់តុលាការចំរុះជាតិនិងអន្តរជាតិ ដែលកាត់សេចក្តីទៅតាមផ្លូវច្បាប់ ។ ប្រៀបដូចព្រះសង្ឃព្រះពុទ្ធសាសនា បើភិក្ខុអង្គណាប្រព្រឹត្តខុសវិន័យ ក៏ត្រូវកាត់សេចក្តីធ្វើទោសតាមព្រះវិន័យដូចគ្នាដែរ ។ បើតាមច្បាប់កម្មផលរបស់ព្រះពុទ្ធ មេខ្មែរក្រហមទាំងនេះដែលបានធ្វើបាបពលរដ្ឋខ្មែរពេញមួយនគរបែបនេះ នឹងត្រូវទទួលទោសទណ្ឌកម្មយ៉ាងធ្ងន់នៅលោកខាងមុខទៀតពុំខាន នៅពេលគាត់ស្លាប់ទៅ ។ ដូច្នេះដើម្បីធ្វើការផ្សះផ្សាជាតិរវាងខ្មែរនិងខ្មែរឡើងវិញ ត្រូវតែមានយុត្តិធម៌ក្នុងសង្គម ជាពិសេសឲ្យមានការកាត់ទោសខ្មែរក្រហមប្រកបដោយយុត្តិធម៌នេះឯង ។

យើងអ្នកកាន់ព្រះពុទ្ធសាសនាបានគាំទ្រការកាត់ទោសនេះ ដោយមើលឃើញប្រយោជន៍១០យ៉ាងគឺ ៖

១- រកយុត្តិធម៌ជូនអ្នករងគ្រោះទាំងអ្នកស្លាប់ទាំងអ្នកនៅរស់

២- អាចឲ្យអ្នកនៅរស់ស្ងប់ផ្លូវចិត្ត

៣- ផ្តន្ទាទោសអ្នកប្រព្រឹត្តខុស

៤- លើកដម្កើងនីតិរដ្ឋ

៥- កុំឲ្យរបបនេះវិលត្រឡប់មកវិញ

៦- ជាការជូនសារមិនត្រឹមតែនៅក្នុងប្រទេសកម្ពុជាទេ គឺទៅកាន់ពិភពលោកទាំងមូលដោយខ្លឹមសារថា អ្នកប្រព្រឹត្តឧក្រិដ្ឋខុសច្បាប់ជាតិនិងអន្តរជាតិហើយត្រូវតែយកមកកាត់ទោស

៧- កុំឲ្យអ្នកជំនាន់ក្រោយ ទាំងប្រជាពលរដ្ឋទាំងអ្នកកាន់អំណាចយកតម្រាប់តាម

៨- បំបាត់ការសងសឹកគ្នា

៩- ផ្សះផ្សាជាតិឡើងវិញ

១០- បិទទំព័រប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតត្រឹមតែប៉ុណ្ណេះ ។

សូមពន្លឿនការកាត់ទោសនេះឲ្យបានឆាប់រហ័ស ព្រោះមេខ្មែរក្រហមទាំងនេះកាន់តែចាស់ជរាណាស់ហើយ ឲ្យបានកាត់ទោសមុនគាត់ស្លាប់ កុំឲ្យស្តាយក្រោយដូចប៉ុល-ពត, តាម៉ុក ត្រូវស្លាប់មុនកាត់ទោស ។ ឯកសារជាភស្តុតាងសំរាប់ធ្វើទឡ្ហីករណ៍ដាក់បន្ទុក ដូចជាមានស្ទើរសព្វគ្រប់អស់ហើយ ។ ថែមពីលើនេះទៀត មជ្ឈមណ្ឌលឯកសារកម្ពុជារបស់លោកឆាំងយុ បានស្រាវជ្រាវរកឃើញភស្តុតាងជាច្រើន ឯកសារសរសេរឮថាមាន៥សែនទំព័រ ក្រៅពីនេះមានឃើញរណ្តៅកប់សពធំៗជាច្រើនកន្លែង រូបថត ភាពយន្ត អ្នកធានាធ្វើជាសាក្សីជាច្រើននាក់ទៀត ។ ដូច្នេះកុំឲ្យយឺតពេល សូមតុលាការប្រឹងប្រែងកាត់

ទោសឲ្យបានឆាប់រហ័ស ។

ព្រឹត្តិការណ៍ឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ សម័យគ្រប់គ្រងរបស់កម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) ជាព្រឹត្តិការណ៍គួរឲ្យរន្ធត់ដោយទុក្ខខ្លោចផ្សា ដែលខ្មែរគ្រប់រូបបានទទួល ។ ប្រទេសបញ្ចប់ចំបាំង ដែលមានទុក្ខវេទនាជាងសង្គ្រាមទៅទៀត ដោយខ្មែរក្រហមបានយករបបកុម្មុយនិស្តដ៏តឹងរ៉ឹង ដែលប្រទេសក្នុងពិភពលោកបានទាត់ចោល មកអនុវត្តតឹងជាងលទ្ធិម៉ៅ-សេទុង ដែលជាចៅហ្វាយខ្លួនទៅទៀត ។ ខ្មែរក្រហមជាជនពាលមិច្ឆទិដ្ឋិ អវិជ្ជា បានអនុវត្តរបៀបគ្រប់គ្រងរបស់ខ្លួនដោយល្ងង់ខ្លៅ ទុកប្រជាពលរដ្ឋខ្មែរទាំងមូលជាទាសករ ។ ខ្មែរក្រហមទោះអះអាងថា អំពើរបស់ខ្លួនទាំងប៉ុន្មានដើម្បីប្រយោជន៍ជាតិក៏ដោយ ប៉ុន្តែមធ្យោបាយធ្វើឲ្យជាតិវិនាស សម្លាប់ខ្មែររាប់លាននាក់ ត្រូវតែទទួលខុសត្រូវក្នុងអំពើឧក្រិដ្ឋរបស់ខ្លួន ។ បើអះអាងថា អ្នកសម្លាប់ជាយួន ត្រូវតែរកភស្តុតាងតទល់ជាមួយតុលាការ ។ យើងសូមរំឭកឡើងវិញ អ្នកដែលធ្វើឲ្យខ្មែរក្រហមឈ្នះគឺសម្តេចនរោត្តម-សីហនុ ដែលសង់សឹកនឹងអ្នកដែលទម្លាក់ព្រះអង្គ ។ សូមខ្មែរគ្រប់រូប មុននឹងជឿអ្នកនយោបាយណាក៏ដោយ ត្រូវពិចារណា កុំចេះតែជឿ ។៚

* *

*